01253710

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 17 / 06 / 2016
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

E400/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៦

**ជូនចំពោះ÷** **ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី÷** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន÷** **លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ÷** **សេចក្តីសម្រេចទទួលយកសម្រង់នៃសៀវភៅដែលនិពន្ធដោយដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី (2-TCCP-243) ធ្វើជាឯកសារភ័ស្តុតាង**

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើមួយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដែលបានដាក់នៅថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៦ ដោយសហមេធាវីនាំមុខតំណាងដើម- បណ្តឹងរដ្ឋប្បវេណី ("សហមេធាវីនាំមុខ") សុំឱ្យទទួលយកសម្រង់ចំនួនបីនៃសៀវភៅដែលនិពន្ធដោយដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី (2-TCCP-243) ដែលមានចំណងជើងថា "*អ្នកនៅរស់៖ ជ័យជំនះរបស់បុរសធម្មតាម្នាក់ក្នុងរបបប្រល័យពូជសាសន៍ខ្មែរក្រហម*" ធ្វើជាភ័ស្តុតាង ("សំណើសុំ") (ឯកសារ E400, E400.2)។ សំណៅជាការជូនដំណឹងនៃសំណើសុំនេះ ត្រូវបានផ្តល់ដល់អង្គជំនុំជម្រះ និង ភាគីនៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៦។ អង្គជំនុំជម្រះបានស្តាប់សេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់ទៅលើសំណើសុំនេះ នៅថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ មុនពេលចាប់ផ្តើមការតាំងសំណួរទៅលើដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-243។ បន្ទាប់ពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់ភាគី ពុំមានភាគីណាមួយជំទាស់ទេ អង្គជំនុំជម្រះបានសម្រេចដោយផ្ទាល់មាត់ទទួលយកសម្រង់នៃសៀវភៅ

នេះ ដោយបញ្ជាក់ថា សំអាងហេតុនឹងចេញនៅពេលក្រោយ (ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ទំព័រ ៣-៨)។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសូមផ្តល់សំអាងហេតុសម្រាប់សេចក្តីសម្រេចរបស់ខ្លួននៅពេលនេះ។

២. អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា សៀវភៅនេះត្រូវបាននិពន្ធដោយដើមបណ្តឹងរដ្ឋប្បវេណី ដែលជាអ្នកនៅរស់រានមានជីវិតម្នាក់ពីមន្ទីរសន្តិសុខ ស-២១ ហើយសម្រង់ដែលត្រូវបានស្នើសុំឱ្យទទួលយកធ្វើជាភ័ស្តុតាងនោះ ពិពណ៌នាអំពីការចាប់ខ្លួន ការឃុំខ្លួន និងការសួរចម្លើយគាត់នៅឯមន្ទីរសន្តិសុខ ស-២១ រួមទាំងព្រឹត្តិការណ៍ផ្សេងៗទៀត។ អង្គជំនុំជម្រះសាលាដំបូងរម្លឹកអំពីការអនុវត្តរបស់ខ្លួនក្នុងការទទួលយកកំណត់ហេតុស្តាប់ចម្លើយមុនៗទាំងអស់របស់សាក្សីដែលផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមវិធាន ៨៧(៣) និង (៤) នៃវិធានផ្ទៃក្នុង (*សូមមើល ឧទា.* ឯកសារ E410)។ វាជាប្រយោជន៍ក្នុងការបញ្ជាក់ការពិត ដែលអង្គជំនុំជម្រះ និង ភាគីទាំងអស់អាចចូលមើលចម្លើយទាំងអស់របស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលនឹងត្រូវផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០២។ លើសពីនេះទៀត ឯកសារទាំងនេះគួរត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដើម្បីអនុញ្ញាតឱ្យមានការវាយតម្លៃឱ្យបានពេញលេញលើសក្ខីកម្មរបស់ពួកគាត់។ អង្គជំនុំជម្រះយល់ឃើញថា សៀវភៅដែលបានស្នើឡើងនេះគឺជាចម្លើយពីមុនរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ដូច្នេះ អង្គជំនុំជម្រះសម្រេចទទួលយកសម្រង់ដែលបានស្នើឡើងនេះ និង ដាក់លេខឯកសារ E3/10595 ទៅសម្រង់នេះ។